# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១៤៩......................ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨-១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អន.ក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់អ្នកស្រី គីម សុជាតិ នាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១

## សម្រេច

**ប្រការ ១** : ត្រូវបានអនុញ្ញាតឱ្យបង្កើតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយដែលមានឈ្មោះថា "មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ" ហៅកាត់ថា "ម.ប.ជ.ត" ជាភាសាអង់គ្លេស "**TATENO JAPANESE TRAINING CENTER**" ហៅកាត់ថា "**T.J.T.C**"។ មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ នេះស្ថិតក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅ ផ្ទះលេខ ៥៦ **BI** ផ្លូវលេខ ២៣០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ ២** : មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ ធ្វើការបណ្តុះបណ្តាលថ្នាក់វិញ្ញាបនបត្រ សិក្សារយៈពេលក្រោម ១ឆ្នាំ មានជំនាញ : ភាសាជប៉ុន ភាសាអង់គ្លេស និងកុំព្យូទ័រ ។

ទៅអនាគត មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ អាចតម្លើងកម្រិតបណ្តុះបណ្តាល និងជំនាញផ្សេងៗទៀតតាមការរីកចម្រើនរបស់មជ្ឈមណ្ឌលដោយសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៣** : លក្ខខណ្ឌទទួលសិស្សឱ្យចូលរៀន : បេក្ខជនទាំងពីរភេទជាសិក្ខាកាម-សិស្ស-និស្សិត-ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ ។

**ប្រការ ៤** : មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ ដឹកនាំដោយនាយិកា ០១រូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ ៥** : នាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ មានភារកិច្ច :

- ជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកមកបម្រើការងារ
- គ្រប់គ្រងឱ្យបានល្អនូវការបង្រៀន ការអនុវត្តន៍ជាក់ស្តែង ការសិក្សា ការប្រឡង និងការប្រគល់វិញ្ញាបនបត្រ
- គោរព និងអនុវត្តតាមសារាចរ និងសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធ្វើរបាយការណ៍រាល់សកម្មភាពបណ្តុះបណ្តាលជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ) ប្រចាំឆមាស/វគ្គនីមួយៗឱ្យបានទៀងទាត់ ។

**ប្រការ ៦** : ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល និងមានសិទ្ធិបិទ ក្នុងករណីមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ នេះអនុវត្តខុសពីច្បាប់រដ្ឋ ។

**ប្រការ ៧** : សិស្សដែលបានរៀនចប់កម្មវិធីសិក្សារបស់មជ្ឈមណ្ឌលនេះ ហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានវិញ្ញាបនបត្រតាមជំនាញដែលបានសិក្សា ។ វិញ្ញាបនបត្រនេះត្រូវផ្តល់ឱ្យដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ ហើយត្រូវទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីសាលានេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៨** : មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ មានក្រុមប្រឹក្សាបច្ចេកទេសដែលមានសមាសភាព ០៣ រូប :

| | |
|---|---|
| ១- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- នាយិកាមជ្ឈមណ្ឌល | អនុប្រធាន |
| ៣- តំណាងសាស្ត្រាចារ្យ ០១ រូប - | សមាជិក |

**ប្រការ ៩** : នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងនាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ មានភារកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ ។

**ប្រការ ១០** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន**

-សាលារាជធានីភ្នំពេញ

" ដើម្បីជ្រាបជាព័ត៌មាន "

-មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាជប៉ុន តាតិណុ

" ដើម្បីអនុវត្ត "

-ដូចប្រការ ៩

-ឯកសារ ន.គ.ក.អ.ប.វ

-កាលប្បវត្តិ